

# អាវធំដែលបាត់

ដោយ ស្បែរឡា ខាញ់ជ្រេដ
ផ្អែកទៅលើដំណើររឿងពិត

*« យើងជាព្រះអម្ចាស់នឹងអត់ទោសដល់អ្នកណា ដែលយើងនឹងអត់ទោស ប៉ុន្តែរីឯអ្នកវិញគឺតម្រូវឲ្យអត់ទោសដល់មនុស្សទាំងអស់ » ( គោលលទ្ធិ និង សេចក្ដីសញ្ញា ៦៤:១០ ) ។*

ប្រាដបាននិយាយថា « ម៉ាក់ ខ្ញុំបាត់អាវធំខ្ញុំហើយ ! វាដល់ពេលចេញពីព្រះវិហារត្រឡប់ទៅផ្ទះវិញ ប៉ុន្តែប្រាដពុំអាចរកឃើញអាវធំគាត់នៅលើស្នាព្យួរអាវឡើយ ។

ម្ដាយបានសួរ តើកូនប្រាកដទេថា កូនពិតជាបានព្យួរវានៅទីនេះ ? »

« បាទ ។ ខ្ញុំបានព្យួរវានៅទីនេះ » ។ អាវធំរបស់ប្រាដគឺពណ៌ខៀវ និងក្រហមស្រស់ ។ វាមិនគួរនឹងបាត់ទេ ។

ប៉ាបាននិយាយថា « ប្រហែលជាមានគេប្ដូរកន្លែងវាហើយ ។ តោះរកមើលជុំវិញអគារ » ។

ម៉ាក់ ប៉ា និង ប្រាដ បានបំបែកផ្លូវគ្នាដើរពិនិត្យមើលបន្ទប់ផ្សេងៗ ។ ពួកគេបានរកមើលនៅក្នុងប្រអប់ដាក់ឥវ៉ាន់រើសបាន នៅក្នុងសាលាជំនុំ នៅក្នុងថ្នាក់សាលាថ្ងៃអាទិត្យរបស់ប្រាដ នៅក្នុងថ្នាក់អង្គការបឋមសិក្សា និងរកនៅលើស្នាព្យួរអាវនីមួយៗ ។ ពួកគេថែមទាំងរកមើលវានៅក្នុងបន្ទប់ទឹកទៀតផង ប៉ុន្តែពួកគេរកវាពុំឃើញឡើយ ។

ប៉ាបាននិយាយថា « ប្រហែលជានរណាម្នាក់បានយកវាច្រឡំហើយ ។ ប៉ាប្រាកដក្នុងចិត្តថា ពួកគេនឹងយកវាត្រឡប់មកវិញនៅសប្ដាហ៍ក្រោយ ពេលគេដឹងថា វាមិនមែនជារបស់ពួកគេ » ។

ម៉ាក់បាននិយាយថា « អំឡុងពេលនេះ កូនអាចពាក់អាវធំចាស់របស់កូនបាន » ។

ប្រាដបានធ្វើមុខក្រញ៉ូវ ។ គាត់មិនចូលចិត្តអាវធំចាស់របស់គាត់ទេ ។ វាស្ដើង ហើរពណ៌ ហើយតូចពេកសម្រាប់គាត់ ។ គាត់ស្រឡាញ់អាវធំពណ៌ក្រហម និងខៀវថ្មីរបស់គាត់ ដែលធ្វើឲ្យគាត់មើលទៅដូចជាវីរៈបុរសម្នាក់ ។





ប្រាដបានគិតថា « ប្រហែលជាគេបានឃើញថា អាវធំរបស់ខ្ញុំស្អាត ហើយគេបានលួចវា » ។ តើរឿងនោះអាចកើតឡើងនៅព្រះវិហារយ៉ាងដូចម្ដេច ? គេស្មានថា មនុស្សគ្រប់រូបនៅទីនោះមានភាពទៀងត្រង់ ។ ប្រាដពុំអនុញ្ញាតឲ្យចោរម្នាក់នោះអាចយកអាវធំនោះឡើយ ។ គាត់មានផែនការមួយ ។ នៅសប្ដាហ៍បន្ទាប់គាត់ពិនិត្យមើលយ៉ាងយកចិត្តទុកដាក់ថា តើនរណាពាក់អាវធំរបស់គាត់ ។ ពេលនោះគាត់នឹងយកវាត្រឡប់មកវិញ ហើយស្រែកថា « ឈប់ភ្លាមទៅអាចោរ ! » ពួកគេនឹងសោកស្ដាយដែលពួកគេបានលួចវាទៅ ។

ប្រាដមិនអាចរង់ចាំដល់ថ្ងៃអាទិត្យដើម្បីអនុវត្តតាមផែនការគាត់ឡើយ ។ ប៉ុន្តែនៅសប្ដាហ៍បន្ទាប់ អាកាសធាតុក្ដៅដែលមិនគួរពាក់អាវធំឡើយ ហើយនៅសប្ដាហ៍បន្ទាប់អាកាសធាតុក៏ក្ដៅផងដែរ ។

នៅថ្ងៃអាទិត្យបន្ទាប់មកទៀត ប្រាដបានមើលក្មេងប្រុសទាំងអស់ក្នុងថ្នាក់អង្គការបឋមសិក្សាដោយការសង្ស័យ ។ តើក្មេងប្រុសខ្ពស់ម្នាក់នោះឬគឺជាចោរ ? ឬប្រហែលជាក្មេងស្រីនោះទេដឹង ? គាត់មានអារម្មណ៍ថា គាត់មិនអាចទុកចិត្តនរណាឡើយ ។ ប្រាដអត់ចូលចិត្តអារម្មណ៍បែបនោះទេ ។

បន្ទាប់ពីចប់ម៉ោងនៅព្រះវិហារ ប្រាដបានប្រញាប់ទៅជុំវិញអគារ ដោយមើលក្រុមគ្រួសារផ្សេងៗពាក់អាវធំរបស់ពួកគេ ។ ប៉ុន្តែគាត់ពុំឃើញអាវធំរបស់គាត់នៅកន្លែងណាទេ ។ គាត់ថែមទាំងបានពិនិត្យមើលប្រអប់ដាក់ឥវ៉ាន់រើសបានទៀត . . . ប៉ុន្តែអត់ឃើញអាវធំគាត់ទេ ។ តើវានៅឯណាទៅ ?

នៅតាមផ្លូវទៅផ្ទះវិញ ប្រាដបានគិតឃើញផែនការថ្មីមួយទៀត ។ គាត់បានអធិស្ឋាន ។ គាត់បានដឹងថា ព្រះវរបិតាសួគ៌រកឃើញវត្ថុដែលបាត់ ។ នៅយប់នោះ ប្រាដបានអធិស្ឋាន ហើយនិយាយថា « ឱព្រះវរបិតាសួគ៌អើយ សូមប្រាប់ទូលបង្គំថា តើនរណាបានយកអាវធំរបស់ទូលបង្គំ ។ ទូលបង្គំចង់បានវាត្រឡប់មកវិញ » ។

ប្រាដបានរង់ចាំមើលក្រែងមានឈ្មោះ ឬមុខរបស់ចោរផុសឡើងក្នុងចិត្តគាត់ ។ ប៉ុន្តែផ្ទុយទៅវិញ គាត់បានចាប់ផ្ដើមគិតអំពីមិត្តគាត់ម្នាក់ឈ្មោះខាល ។ ប្រាដតែងតែអង្គុយនៅក្បែរខាលនៅក្នុងថ្នាក់អង្គការបឋមសិក្សា ។ ពួកគេនិយាយរឿងកំប្លែង និងសើចច្រើនជាមួយគ្នា ។ ប៉ុន្តែខាលពុំបានមកព្រះវិហារពីរបីសប្ដាហ៍ហើយ ។ ប្រាដបាននឹកគាត់ ។

តើមានអ្វីកើតឡើងទៅ បើ *ខាល* បានយកអាវធំរបស់គាត់នោះ ? ប្រហែលជាខាលខ្លាចអត់ហ៊ានមកព្រះវិហារឥឡូវនេះ ដោយសារគាត់បានគិតថា ប្រាដពុំធ្វើមិត្តនឹងគាត់ទៀតទេ ។ ប្រាដចង់ឲ្យខាលមកព្រះវិហារវិញម្ដងទៀត ។ ប្រសិនបើខាលបានយកអាវធំគាត់មែន នោះប្រាដបានសម្រេចចិត្តថា គាត់នឹងពុំស្រែកដាក់ខាលទេ ។ គាត់នឹងអភ័យទោសឲ្យខាល ។

ប្រាដបានឡើងលើគ្រែ ដោយមានអារម្មណ៍ល្អជាងមុន ។

នៅថ្ងៃអាទិត្យបន្ទាប់ក្នុងថ្នាក់អង្គការបឋមសិក្សា ខាលពុំបាននៅក្នុងថ្នាក់ទេ ប៉ុន្តែមានក្មេងប្រុសថ្មី ម្នាក់នៅក្នុងថ្នាក់បឋមសិក្សា ។ គាត់ពាក់ក្រវ៉ាត់កក្រហមឆ្នូតខៀវ ។

ដោយអង្គុយនៅក្បែរក្មេងប្រុសថ្មីនោះ ប្រាដបាននិយាយថា « ក្រវ៉ាត់កស្អាតណាស់ ។ វាធ្វើឲ្យអ្នកមើលទៅដូចជាវីរៈបុរសអញ្ចឹង ។

ក្មេងប្រុសនោះបានញញឹម ។

ប្រាដបានញញឹមផងដែរ ។ គាត់ឈប់រកមើលចោរទៀតហើយ ។ គាត់រកមើលមិត្តភក្ដិវិញម្ដង ។●

*អ្នកនិពន្ធរស់នៅរដ្ឋ អៃអូវ៉ា ស.រ.អា. ។*